# សុន្ទរកថារបស់លោកអ៊ីអ៊ីស៊ីកា តូម៉ុហ៊ីរ៉ូ
# លេខាទីពីរ ស្ថានទូតជប៉ុន
# ថ្លែងក្នុងពិធីសម្ពោធប្រព័ន្ធលូរំដោះទឹកក្នុងតំបន់អូរតាវ៉ៅ ខេត្តប៉ៃលិន
# ថ្ងៃទី០៥ ខែមិនា ឆ្នាំ២០១៣៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**

**សូមគោរព ឯកឧត្តម អ៊ី ឈាន អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន!**

**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ ដោយបានចូលរួមក្នុងពិធីសម្ពោធប្រព័ន្ធលូរំដោះទឹកក្នុងតំបន់អូរតាវ៉ៅ ខេត្តប៉ៃលិនជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម អ៊ី ឈាន អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន។ ជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន និងប្រជាជនក្នុងតំបន់ដែលបានរៀបចំឲ្យមានកម្មវិធីនេះឡើង។

ការការពារទឹកជំនន់គឺជាវិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្តែងគម្រោងកែលម្អប្រព័ន្ធលូរំដោះទឹកជាច្រើនត្រូវបានអនុវត្តទាំងនៅទីក្រុង និងតំបន់ជនបទ។ តួយ៉ាងនៅក្នុងខេត្តប៉ៃលិន គម្រោងសាងសង់ ផ្លូវបង្ហៀរទឹកចំនួន៣កន្លែង និង លូចំនួន១៤កន្លែង តាមបណ្តោយផ្លូវកសិកម្មមួយក្នុងតំបន់អូរតាវ៉ៅទើបត្រូវបានអនុវត្តថ្មីៗនេះ។

ខ្ញុំបានទទួលដំណឹងថាជាមួយនឹងគម្រោងសាងសង់ប្រព័ន្ធលូរំដោះទឹកក្នុងតំបន់អូរតាវ៉ៅនេះ កសិករនិងប្រជាជន ជាង ៣,០០០នាក់ ដែលរស់នៅក្នុងភូមិចំនួន៥ នឹងមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់សាលាសង្កាត់ មន្ទីរពេទ្យខេត្ត និងសាលារៀនផងដែរ។ យើងក៏សង្ឃឹមថាគម្រោងនេះនឹងរួមចំណែកលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈ ភ្ញៀវទេសចរណ៍ដែលមកកំសាន្ត នៅរមណីយដ្ឋានទឹកជ្រោះភ្នំខៀវក្នុងតំបន់អូរតាវ៉ៅនេះប្រមាណ៦ម៉ឺននាក់ក្នុងមួយឆ្នាំៗផងដែរ។

ខ្ញុំសង្ឃឹមថា មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន នឹងថែទាំប្រព័ន្ធលូរំដោះទឹកនេះឲ្យបានល្អ ដើម្បីអ្នកទទួលផលអាចប្រើប្រាស់សមិទ្ធផលទាំងនេះបានយ៉ាងមានប្រសិទ្ធភាព។

ជាចុងក្រោយ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាប្រព័ន្ធលូរំដោះទឹកនេះនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ ព្រមទាំងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!